multi cultural health communication

NSW GOVERNMENT Health

Khmer
[DOH-7140]

# ជម្ងឺលីពតូស្ពីរ៉ូហ្ស៊ី (Leptospirosis)

## Leptospirosis

### តើជម្ងឺ Leptospirosis ជាអ្វី?

Leptospirosis ជាជម្ងឺបណ្តាលមកពីបាក់តេរីដែលឃាយឺមនុស្សនិងសត្វពាហនៈ ។ ជម្ងឺនេះបណ្តាលមកពីបាក់តេរី ឈ្មោះ Leptospira ដែលមាននៅក្នុងទឹកនោមនិងជាលិការរបស់សត្វពាហនៈមានផ្ទុកមេរោគនេះ ។

### តើជម្ងឺនេះមានរោគសញ្ញាអ្វីខ្លះ ?

រោគសញ្ញាចាប់ផ្តើមទូទៅជាងគេនៃជម្ងឺ Leptospirosis គឺ : ក្តៅខ្លួន, ឈឺក្បាលខ្លាំង, ឈឺសាច់ដុំ, រងាញាក់, ក្អួត និងភ្នែកឡើងក្រហម ។ រោគសញ្ញាទាំងអស់នេះអាចមានលក្ខណៈដូចជម្ងឺផ្សេងទៀតដែរ មានដូចជាជម្ងឺផ្តាសាយធំ ហើយជាញឹកញាប់ពិបាកធ្វើរោគវិនិច្ឆ័យ ។ មនុស្សខ្លះមិនមានរោគសញ្ញាទាំងនេះទេ ។

មនុស្សខ្លះដែលបានឆ្លង Leptospirosis ក៏វិវឌ្ឍទៅជាជម្ងឺធ្ងន់ធ្ងរ។ នេះអាចរួមបញ្ចូលទាំងជម្ងឺ Weil ដែលបណ្តាលឲ្យតំរងនោមចុះខ្សោយ, និងកើតលឿង (ស្បែកឡើងពណ៌លឿងដែលបង្ហាញថាមានជម្ងឺថ្លើម) ហើយមានហូរឈាមនៅក្នុងស្បែកនិងភ្នាសជាលិកា។ ជម្ងឺរលាកស្រោមខួរក្បាលនិងការហូរឈាមនៅក្នុងសួតអាចកើតឡើងផងដែរ។ មនុស្សភាគច្រើនដែលវិវឌ្ឍទៅរកសភាពធ្ងន់ធ្ងរត្រូវតែសំរាកព្យាបាលក្នុងមន្ទីរពេទ្យ ហើយជួនកាលសភាពធ្ងន់ធ្ងរនៃ Leptospirosis អាចប៉ះពាល់ដល់អាយុជីវិត ។

### តើផលប៉ះពាល់រយៈពេលវែងនៃជម្ងឺនេះអ្វីខ្លះ ?

ភាពធូរស្រាលឡើងវិញពីជម្ងឺ Leptospirosis អាចមានសភាពយឺត ។ មនុស្សអាចមានជម្ងឺដូចជា អស់កម្លាំងរ៉ាំរ៉ៃ ដែលនឹងមានរយៈពេលជាច្រើនខែ ។ អាការរោគផ្សេងទៀតអាចកើតមានឡើង ដូចជាឈឺក្បាលមិនបាត់ និងការពិបាកចិត្ត ។ ជួនកាលបាក់តេរីអាចនៅមានក្នុងភ្នែកហើយបណ្តាលឲ្យមានការរលាកភ្នែករ៉ាំរ៉ៃ ។

### តើជម្ងឺនេះឆ្លងយ៉ាងដូចម្តេច ?

ជាទូទៅបាក់តេរី Leptospira ចូលទៅក្នុងរាងកាយរបស់មនុស្សតាមរយៈស្បែកដាច់ឬរលាត់ ហើយជួនកាលតាមរយៈភ្នាសក្រអូមមាត់ ច្រមុះនិងភ្នែក ។ សត្វពាហនៈជាច្រើនប្រភេទអាចមានផ្ទុកបាក់តេរី Leptospira នៅក្នុងតំរងនោមរបស់វា ។ ការឆ្លងមេរោគអាចកើតឡើង បន្ទាប់ពីការប៉ះពាល់ជាមួយទឹកនោមឬសាច់សត្វពាហនៈដែលមានរោគ ។ ដី ភក់ និងទឹកដែលមានការប្រឡាក់ប្រឡូសនឹងទឹកនោមសត្វ អាចជាប្រភពនៃការបង្ករោគ ។ ជារឿយៗការបរិភោគចំណីអាហារ ឬទឹក ដែលមានមេរោគ គឺជាមូលហេតុនៃការឆ្លងមេរោគ ។

**ជាទូទៅ តើសត្វពាហនៈណាខ្លះដែលមានការពាក់ព័ន្ធនឹងការឆ្លងមេរោគនេះ?**

ប្រភេទសត្វជាច្រើនដែលចិញ្ចឹមកូនដោយទឹកដោះ អាចមានផ្ទុកបាក់តេរី Leptospira ។ នៅប្រទេសអូស្ត្រាលី, ពពួកសត្វ ដែលចំលងញឹកញាប់ជាងគេបំផុតគឺ : កណ្តុរប្រមេះ, កណ្តុរប្រែង, ឆ្កែ, គោក្របី, សត្វស្រុក, ជ្រូក (ទាំងជ្រូកព្រៃ និងជ្រូកស្រុក), សេះ, ឆ្មា និង ចៀម។ សត្វដែលមានរោគ អាចមានរោគសញ្ញានៃជម្ងឺនេះ ឬអាចមិនមានទាល់តែសោះ។

**តើនរណាប្រឈមនឹងគ្រោះថ្នាក់នៃការឆ្លងជម្ងឺនេះ ?**

អ្នកប្រឈមគ្រោះថ្នាក់គឺជនទាំងឡាយណាដែលប៉ះពាល់យ៉ាងស្និទ្ធស្នាលជាមួយសត្វពាហនៈ ឬជនទាំងឡាយណាដែលប៉ះពាល់ជាមួយទឹក ភក់ ដី ឬ ដីដាំដំណាំ ដែលមានប្រឡាក់ប្រឡូសទឹកនោមសត្វ។ ការងារខ្លះប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ (ឧទាហរណ៍ អ្នកចំការ ពេទ្យសត្វ អ្នកធ្វើការនៅកន្លែងសម្លាប់សត្វ កសិករធ្វើការនៅចំការអំពៅ និងចេក)។ សកម្មភាពកំសាន្តខ្លះដែលពាក់ព័ន្ធនឹងការប៉ះពាល់ជាមួយទឹកឬដីដែលមានមេរោគ ក៏អាចបណ្តាលឲ្យឆ្លងមេរោគ Leptospira ផងដែរ (ឧទាហរណ៍ ការបោះជំរុំ, ការធ្វើសួនច្បារ, អ្នកដើរព្រៃ, ការជិះក្បូនកំសាន្ត និងកីឡាតាមទឹកផ្សេងៗទៀត) ។

ទោះបីជាក្នុងមួយឆ្នាំៗ ជម្ងឺ Leptospirosis មានតិចតួចនៅក្នុងប្រទេសអូស្ត្រាលីក៏ដោយ តែជម្ងឺនេះច្រើនសម្បូណ៌នៅតំបន់ក្តៅហើយសើម ដូចជាភាគឦសាន្តនៃរដ្ឋ NSW និងរដ្ឋ Queensland ។ ក្នុងមួយឆ្នាំៗ គេបានធ្វើរោគវិនិច្ឆ័យមួយ ទៅលើករណីប្រហែល ២០០ នៅទូទាំងប្រទេស តែទោះយ៉ាងណាក៏ដោយ ក៏ប្រហែលជាមានករណីជាច្រើនអាចមិនបានទទួលការពិនិត្យធ្វើរោគវិនិច្ឆ័យដែរ ។ ជាញឹកញាប់ បុរសឆ្លងជម្ងឺ Leptospirosis ច្រើនជាងស្ត្រី ។

**តើគេធ្វើរោគវិនិច្ឆ័យយ៉ាងដូចម្តេច ?**

វេជ្ជបណ្ឌិតអាចសង្ស័យអំពីការមានជម្ងឺ Leptospirosis លើអ្នកណាម្នាក់ដែលមានរោគសញ្ញាស្តែងចេញឡើងដែលតាមធម្មតា កើតមានឡើងក្នុងពេលពីមួយទៅពីរសប្តាហ៍បន្ទាប់ពីការឆ្លងមេរោគរួច។ ជាទូទៅការបញ្ជាក់អំពីជម្ងឺLeptospirosis ធ្វើឡើងតាមរយៈការធ្វើតេស្តឈាម ដែលបង្ហាញឲ្យឃើញវត្តមានបាក់តេរី Leptospirosis ។ ជាទូទៅគេត្រូវការធ្វើតេស្តឈាមពីដង ក្នុងចន្លោះពេលជាង២អាទិត្យពីគ្នា ដើម្បីធ្វើរោគវិនិច្ឆ័យ។ ជួនកាលគេអាចបណ្តុះបាក់តេរីនេះ ពីឈាម, ទឹកខួរឆ្អឹងខ្នងនិងទឹកនោម ។

**តើគេមានវិធីណាមួយសំរាប់ព្យាបាលជម្ងឺនេះទេ ?**

ជាទូទៅគេព្យាបាលជម្ងឺ Leptospirosis នេះ ដោយប្រើអង់ទីប៊ីយ៉ូទិក មានដូចជា doxycycline ឬ penicillin ។ ដោយសារការធ្វើតេស្តត្រូវចំណាយពេលវេលាខ្លះហើយជម្ងឺអាចវិវឌ្ឍទៅរកភាពធ្ងន់ធ្ងរនោះ វេជ្ជបណ្ឌិតអាចជ្រើសរើសការចាប់ផ្តើមប្រើអង់ទីប៊ីយ៉ូទិកមុនការបញ្ជាក់រោគវិនិច្ឆ័យដោយការធ្វើតេស្ត។ ការព្យាបាលដោយអង់ទីប៊ីយ៉ូទិកត្រូវបានគេគិតថា មានប្រសិទ្ធភាពបំផុតប្រសិនបើចាប់ផ្តើមភ្លាម នៅពេលជម្ងឺចាប់ផ្តើម។

**តើគេបង្ការជំងឺ Leptospirosis យ៉ាងដូចម្តេច ?**

គេមានវិធីជាច្រើនដើម្បីបង្ការជម្ងឺ Leptospirosis ។

**សំរាប់មនុស្សដែលធ្វើការជាមួយសត្វពាហនៈ**

- រុំកន្លែងដាច់និងរលាត់ដោយក្រណាត់មិនជ្រាបទឹក
- ប្រើសំលៀកបំពាក់ការពារ (ឧទាហរណ៍ ពាក់ស្រោមដៃ, ពាក់វ៉ែនតាការពារភ្នែក, អាវអៀមនិងស្បែកជើងកវែង) នៅពេលធ្វើការជាមួយសត្វពាហនៈដែលអាចផ្ទុកមេរោគ ជាពិសេសបើមានឱកាសអ្វីមួយលែធ្វើឲ្យមានការប៉ះពាល់ទឹកនោមសត្វ ។
- ពាក់ស្រោមដៃនៅពេលកាន់សុកគោក្របី ឬ សត្វងាប់ក្នុងពោះ ឬកូនរលូត ឬខ្មោចសត្វ
- ត្រូវមុជទឹកបន្ទាប់ពីធ្វើការហើយ ហើយត្រូវលាងនិងសំងួតដៃបន្ទាប់ពីប៉ះកាន់សំភារៈដែលអាចមានលទ្ធភាពផ្ទុកមេរោគ ។
- មិនត្រូវបរិភោគ ឬ ជក់បារីនៅពេលកាន់ឬប៉ះពាល់សត្វដែលអាចមានផ្ទុកមេរោគឡើយ ។ លាងនិងសំងួតដៃមុនពេលជក់បារីនិងបរិភោគអាហារ ។
- ត្រូវចាក់ថ្នាំការពារសត្វតាមសំនូមពរនៃគ្រូពេទ្យសត្វរបស់លោកអ្នក។
- សំរាប់មនុស្សផ្សេងទៀត ៖
- ជៀសវាងហែលទឹកនៅកន្លែងណាដែលអាចមានទឹកនោមសត្វ ។
- រុំកន្លែងដាច់ និងរលាត់ដោយក្រណាត់មិនជ្រាបទឹកមុនពេលប៉ះពាល់ដី, ភក់ ឬ ទឹកដែលអាចមានទឹកនោមសត្វ។
- ពាក់ស្បែកជើងកវែងពេលចេញក្រៅជាពិសេសនៅពេលដើរកាត់ភក់និងដីសើម ។
- ពាក់ស្រោមដៃពេលធ្វើការនៅសួនច្បារ
- ត្រួតពិនិត្យពពួកសត្វកកេរដោយសំអាតសំរាមនិងយកអាហារចេញពីកន្លែងដែលនៅក្បែរផ្ទះ ។
- មិនត្រូវផ្តល់គ្រឿងក្នុងសត្វដែលនៅឆៅទៅឲ្យឆ្កែស៊ីទេ
- លាងដៃជាមួយសាប៊ូ ព្រោះបាក់តេរី Leptospira ងាប់យ៉ាងឆាប់រហ័ស ដោយសាប៊ូ ថ្នាំសំលាប់មេរោគនិងការសំងួត ។

**តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំកើតជម្ងឺនេះ ?**

បើសិនអ្នកបានកើតជម្ងឺក្នុងរយៈពេលប៉ុន្មានសប្តាហ៍បន្ទាប់ពីអាចមានការប៉ះពាល់ទឹកនោមសត្វពាហនៈ ឬ បរិស្ថាន ដែលមានផ្ទុកមេរោគនោះ ជាការសំខាន់ណាស់ដែលលោកអ្នកប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក អំពីការប៉ះពាល់នេះ ។

**តើគេមានវ៉ាក់សាំងទេ ?**

គេគ្មានវ៉ាក់សាំងការពារមនុស្សប្រឆាំងនឹងជម្ងឺ Leptospirosis ដែលមានការអនុញ្ញាតឲ្យប្រើប្រាស់នៅប្រទេសអូស្ត្រាលីនេះទេ ។ វ៉ាក់សាំងមានសំរាប់តែបង្ការជម្ងឺ Leptospirosis ចំពោះសត្វពាហនៈ (គោ ក្របី ជ្រូក និងឆ្កែ) ប៉ុណ្ណោះ ប៉ុន្តែសត្វ ដែលបានទទួលវ៉ាក់សាំង នៅតែអាចឆ្លងមេរោគប្រភេទផ្សេងទៀត ដែលវ៉ាក់សាំងនេះមិនអាចការពារបាន។

**តើមាននរណាម្នាក់អាចឆ្លងជម្ងឺនេះលើសពីមួយដងទេ ?**

ដោយសារតែបាក់តេរី Leptospira មានច្រើនប្រភេទផ្សេងៗគ្នានោះ វាអាចធ្វើឲ្យមនុស្សណាម្នាក់ឆ្លងមេរោគនៃអំបូរផ្សេងទៀត ហើយកើតជម្ងឺ Leptospirosis នេះម្តងទៀតបាន។



NSW Multicultural Health Communication Service
Website: http://www.mhcs.health.nsw.gov.au
Email: mhcs@sesiahs.health.nsw.gov.au
Tel: (02) 9816 0347

**តើមនុស្សដែលមានជម្ងឺ Leptospirosis អាចឆ្លងទៅមនុស្សផ្សេងទៀតឬទេ ?**

ជាករណីកំរដែលជម្ងឺ Leptospirosis អាចឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតបាន (ឧទាហរណ៍ ឆ្លងតាមរយៈការរួមភេទនិងតាមរយៈទឹកដោះម្តាយ ។ បាក់តេរី Leptospira អាចឆ្លងតាមរយៈទឹកនោម អស់រយៈពេលជាច្រើនខែបន្ទាប់ពីការបង្ករោគរួច។

## ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW



**1300 066 055**

**www.health.nsw.gov.au**